ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកត្រពាំងប្រាសាទ
អង្គភាពលទ្ធកម្ម
លេខ : ១៩០/១៦.....អលៈត្រ/ស

# សេចក្តីជូនដំណឹង
## ស្តីពី

ការអញ្ជើញចូលរួមពិគ្រោះថ្លៃការងារជួសជុលផ្លូវលំក្រាលក្រួសក្រហមប្រវែង ១,៣៦៦ ម៉ែត្រនិងលូកាត់ផ្លូវ០១កន្លែង ពីភូមិឈូកស ឃុំត្រពាំងប្រាសាទ ទៅដល់ភូមិតាសំ ឃុំ អូរស្វាយ ស្រុកត្រពាំងប្រាសាទ ជូនរដ្ឋបាលស្រុកត្រពាំងប្រាសាទ

អង្គភាពលទ្ធកម្មនៃរដ្ឋបាលស្រុកត្រពាំងប្រាសាទ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អង្គភាពលទ្ធកម្មនៃរដ្ឋបាលស្រុកត្រពាំងប្រាសសាទ នឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារជួសជុលផ្លូវលំក្រាលក្រួសក្រហមប្រវែង ១,៣៦៦ ម៉ែត្រ និងលូកាត់ផ្លូវ០១កន្លែង ពីភូមិឈូកស ឃុំត្រពាំងប្រាសាទ ទៅដល់ភូមិតាសំ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ជូនរដ្ឋបាលស្រុកត្រពាំងប្រាសាទ ។

អង្គភាពលទ្ធកម្មស្រុកបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មស្រុកត្រពាំងប្រាសាទ ដែលមាន អាសយដ្ឋាន ភូមិទួលតាសេក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចាប់ពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ 097 264 283 6 ឬ email : sith.royal8@gmail.com ) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ វេលាម៉ោង ០៩ ព្រឹក ។

ការបើកសំណើពិគ្រោះថ្លៃ នឹងប្រព្រឹត្តទៅនៅរដ្ឋបាលស្រុកត្រពាំងប្រាសាទ តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៩ ព្រឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។ ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។

ធ្វើនៅត្រពាំងប្រាសាទ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦
ប្រធានគណៈកម្មាធិការលទ្ធកម្ម

ចៅសំ តារារិទ្ធ

ចម្លងជូន ៖
- សាលាខេត្ត ឧត្តរមានជ័យ
- ទីចាតការផែនការវិនិយោគ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត